ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី
លេខ: ១៦៧
ចុះថ្ងៃទី០២.០២.២០១១

សាលក្រម
លេខ: ៣៣ "ច"
ចុះថ្ងៃទី១០.០៨.២០១១

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១
សាលក្រមប្រកាសជាសាធារណៈ នាថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១

សមាសភាពជំនុំជម្រះ

- លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ។
- លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ។
- លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ។

រវាង ដើមចោទឈ្មោះ [redacted] ទូចស៊ាង ភេទស្រី អាយុ ៤៣ឆ្នាំ ទីលំនៅផ្ទះលេខ៥៤AE₀E, ផ្លូវលេខ២០៤ ក្រុមទី១៥ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ឪពុកឈ្មោះ [redacted] ឈីវគង់(ស) ម្តាយឈ្មោះ [redacted] អេង(ស) ប្តីឈ្មោះ [redacted] សុភាណា មានកូន ០៣នាក់ ។ តំណាងដោយអាណត្តិមេធាវី [redacted]

និង ចុងចម្លើយឈ្មោះ [redacted] សុភាណា ភេទប្រុស អាយុ ៤៣ឆ្នាំ ទីលំនៅផ្ទះលេខ៥៤AE₀E, ផ្លូវលេខ២០៤ ក្រុមទី១៥ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ឪពុកឈ្មោះ [redacted] តាយ (រ) ម្តាយឈ្មោះ [redacted] ឆេងលន(រ) ប្រពន្ធឈ្មោះ [redacted] ទូចស៊ាង មានកូន ០៣នាក់ ។ តំណាងដោយអាណត្តិមេធាវី [redacted]

### អង្គហេតុ និងចំណុចវិវាទ

១-ការប្តឹងទាមទាររបស់ដើមចោទ:

-ប្តឹងសុំលែងលះពីប្តីឈ្មោះ [redacted] សុភាណា។

-ប្តឹងសុំសិទ្ធិគ្រប់គ្រងកូន និងអាហារកិច្ចចិញ្ចឹមកូន។

-ប្តឹងសុំបែងចែកទ្រព្យរួម ។

២-ការអះអាងរបស់គូភាគី:

ក-ដើមចោទឈ្មោះ [redacted] ទូចស៊ាង បានថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា: ខ្លួនបានរៀបការជាមួយចុងចម្លើយឈ្មោះ [redacted] សុភាណា កាលពីឆ្នាំ១៩៨៨ ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ទេ។ ក្រោយពីបានរៀបការរួចមកខ្លួនមិនមានសេចក្តីសុខដូចគ្រួសារដទៃទេ ដោយសារការរស់នៅមិនមានភាពចុះសំរុងគ្នា និង

ឈ្មោះប្រកែកគ្នាជាញឹកញាប់ ព្រមទាំងមានការជេរប្រមាថមើលងាយខ្លួនគ្រប់បែបយ៉ាង។ មិនតែប៉ុណ្ណោះចុងចម្លើយឈ្មោះ [redacted] សុភាពណ តែងតែប្រើអំពើហិង្សាមកលើរូបខ្លួនទៀតផង។ ទង្វើទាំងនេះបណ្តាលឱ្យខ្លួនអស់មនោសញ្ចេតនាជាប្តីប្រពន្ធ។ ការរស់នៅជាមួយគ្នាជាប្តីប្រពន្ធមានកូនបីនាក់គឺឈ្មោះ [redacted] សុភារ៉ា ភេទប្រុស កើតនៅថ្ងៃទី០២.០១.១៩៩២.ឈ្មោះឈាង សៅរ៍មករា ភេទប្រុស កើតនៅថ្ងៃទី២៧.០១.១៩៩៦ និងឈ្មោះ [redacted] គីមលាង ភេទស្រី កើតនៅថ្ងៃទី២១.០៩.២០០៦ គឺខ្លួនសុំសិទ្ធិគ្រប់គ្រងកូនដែលជាអនីតិជន ដោយប្តឹងទាមទារអាហារកិច្ចចិញ្ចឹមកូនជាអនីតិជនទាំងពីរនាក់ក្នុងមួយខែចំនួន ៣០០USD។ រីឯកូនឈ្មោះ [redacted] សុភារ៉ា ដែលជានីតិជន គឺខ្លួនមិនសុំសិទ្ធិគ្រប់គ្រងទេ។ បច្ចុប្បន្ននេះ គឺខ្លួនមានមុខរបរជាអ្នកលក់ខោអាវនៅផ្សារអូរឡាំពិច ដោយចុងចម្លើយឈ្មោះ [redacted] សុភាពណ គឺគ្រាន់តែមានកំលាំង និងជួយរៀបចំឥវ៉ាន់ឱ្យខ្លួនតែប៉ុណ្ណោះ។ ចំពោះទ្រព្យរួម មាន:

១-ផ្ទះលេខ៥៥៤$AE_0E_1$ ផ្លូវលេខ២០៤ ក្រុមទី១៥ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ១៣៨៨/០៧ ចុះថ្ងៃទី០១.០៨.២០០៧ របស់អភិបាលខណ្ឌទួលគោក ។

២-ដីទំហំ ២៥៥០ម៉ែត្រការេ មានទីតាំងស្ថិតនៅភូមិបង្គោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ៤៤៩/០៨ ឃអព ចុះថ្ងៃទី២១.០៨.២០០៨ របស់មេឃុំអំពិល។

៣-សិទ្ធិជួលតូបលេខ៣៥៦ និងលេខ៣៦៦ អាគារ $C_0$ ក្នុងមជ្ឈមណ្ឌលពាណិជ្ជកម្មអូឡាំពិច។

៤-បំណុលរួមក្នុងការរកស៊ីជាមួយគ្នាមាន ១០៨.៨៨៤ USD។

គឺខ្លួនសុខចិត្តបែងចែកទ្រព្យរួម នូវៈ ផ្ទះលេខ៥៥៤$AE_0E_1$ ផ្លូវលេខ២០៤ ក្រុមទី១៥ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ និងដីទំហំ ២៥៥០ម៉ែត្រការេ មានទីតាំងស្ថិតនៅភូមិបង្គោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ ចំណែកឯ សិទ្ធិជួលតូបលេខ៣៥៦ និងលេខ៣៦៦ អាគារ $C_0$ គឺខ្លួនប្តឹងសុំសិទ្ធិគ្រប់គ្រង ពីព្រោះខ្លួនមានអាជីពជាអ្នកលក់ដូរខោអាវដើម្បីចិញ្ចឹមជីវិតកូនទាំងបីនាក់នៅក្នុងបន្ទុក។រីឯបំណុលរួម គឺខ្លួនប្តឹងសុំឱ្យចុងចម្លើយឈ្មោះ [redacted] សុភាពណ ទទួលបន្ទុករួមជាមួយខ្លួនដែរ។ ចំណែកឯទ្រព្យដោយឡែក គឺគ្មានទេ។ ចំពោះប្រាក់ប្រដាប់ក្តី គឺខ្លួនសុខចិត្តទទួលបន្ទុក ពីព្រោះប្រាក់នេះខ្លួនបានបង់រួចហើយ។

សំណូមពរ: សុំឱ្យតុលាការចេញសាលក្រមទទួលស្គាល់ការឈប់រស់នៅជាអនីតិសង្វាសពីប្តីឈ្មោះ [redacted] សុភាពណ និងសុំសិទ្ធិគ្រប់គ្រងកូនទាំងពីរនាក់ព្រមទាំងអាហារកិច្ចចិញ្ចឹមកូន និងបែងចែកទ្រព្យរួម និងគ្រប់គ្រងសិទ្ធិជួលតូបទាំងពីរ។

ខ-តំណាងដោយអាណត្តិឱ្យដើមចោទមេធាវី [redacted] បានថ្លែងការណ៍ថា: ខ្លួនឯកភាពតាមការថ្លែងការណ៍របស់កូនក្តីខ្លួនឈ្មោះ [redacted] វួចស៊ាង ទាំងស្រុងដោយគ្មានអ្វីបន្ថែមទៀតទេ ។

គ-ចុងចម្លើយឈ្មោះ [redacted] សុភាពណ បានថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា: ខ្លួនពិតជាបានរៀបការជាមួយដើមចោទឈ្មោះ [redacted] វួចស៊ាង កាលពីឆ្នាំ១៩៨៨ ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ប្រាកដមែន។ ខ្លួនឯកភាពក្នុងការឈប់រស់នៅជាអនីតិសង្វាសជាមួយដើមចោទឈ្មោះ [redacted] វួចស៊ាង។ ចំពោះកូន គឺខ្លួនឯកភាពប្រគល់សិទ្ធិគ្រប់គ្រងកូនទាំងពីរនាក់ដែលជាអនីតិជន ឱ្យទៅដើមចោទឈ្មោះ [redacted] វួចស៊ាង តាមការប្តឹងសុំដោយខ្លួនសុំបង់



Scanned with CamScanner

អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាពដែលខ្លួនមាន ។ រីឯ កូនម្នាក់ទៀត គឺជានីតិជន ។ ចំណែកឯទ្រព្យរួម គឺមានដូចការថ្លែងការណ៍របស់ដើមចោទឈ្មោះ[redacted] វូចស៊ាង លើកលែងតែបំណុលរួមចំនួន ១០៨,៨៨៤USD គឺខ្លួនមិនទទួលស្គាល់ទេ ។ ចំពោះ ទ្រព្យដោយឡែក គឺគ្មានទេ ។

សំណូមពរ: សុំឱ្យតុលាការចេញសាលក្រមទទួលស្គាល់ការឈប់រស់នៅជាអនីតិសង្វាសពីប្រពន្ធឈ្មោះ[redacted] វូចស៊ាង និងសុំឱ្យបែងចែកទ្រព្យរួម ។

ឃ-តំណាងដោយអាណត្តិឱ្យចុងចម្លើយមេធាវី[redacted] បានថ្លែងការណ៍ថា: ខ្លួនឯកភាពតាមការថ្លែងការណ៍របស់កូនក្តីខ្លួនឈ្មោះ[redacted] សុភាណា ទាំងស្រុងដោយគ្មានអ្វីបន្ថែមទៀតទេ ។

ង-តំណាងដោយអាណត្តិឱ្យដើមចោទមេធាវី[redacted] បានថ្លែងការណ៍បញ្ជាក់ថា: ចំពោះសិទ្ធិជួលតូបលេខ៣៥៦ និងលេខ៣៦៦ អាគារ $C_0$ គឺកូនក្តីខ្លួនឈ្មោះ[redacted] វូចស៊ាង បានជួលពីក្រុមហ៊ុនក្នុងរយៈពេល២០ឆ្នាំ ដោយកូនក្តីខ្លួនបានបង់ប្រាក់ជួលឱ្យទៅក្រុមហ៊ុនជារៀងរាល់ខែ ហើយបំណុលរួម គឺមានដូចកូនក្តីខ្លួនបានថ្លែងការណ៍ គឺជំពាក់គេចំនួន ១០៨,៨៨៤USD ។

សំណូមពរ: សុំឱ្យតុលាការសម្រេចតាមការប្តឹងសុំរបស់កូនក្តីខ្លួនឈ្មោះបេ វូចស៊ាង ។

ច-តំណាងដោយអាណត្តិឱ្យចុងចម្លើយមេធាវី[redacted] បានថ្លែងការណ៍បញ្ជាក់ថា: ខ្លួនសំណូមពរសុំឱ្យតុលាការសម្រេចបែងចែកទ្រព្យរួមតាមការប្តឹងសុំរបស់កូនក្តីខ្លួនឈ្មោះ[redacted] សុភាណា ។ ចំពោះបំណុលរួម គឺកូនក្តីខ្លួនបានបដិសេធមិនទទួលស្គាល់ ដោយវិក័យប័ត្រដែលដើមចោទឈ្មោះ[redacted] វូចស៊ាង បានដាក់ជូនតុលាការពិនិត្យនោះ គឺធ្វើឡើងក្រោយពេលមានទំនាស់ និងមិនមានចុះហត្ថលេខា ឬស្នាមមេដៃរបស់កូនក្តីខ្លួនក្នុងការទទួលស្គាល់ ដែលលិខិតស្នាមនេះធ្វើឡើងមិនស្របតាមមាត្រា១៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនោះឡើយ ។ ចំពោះអាហារកិច្ចចិញ្ចឹមកូន គឺសព្វថ្ងៃកូនក្តីខ្លួនមិនមានលទ្ធភាពផ្តល់អាហារកិច្ចចិញ្ចឹមកូនជាអនីតិជនទាំងពីរនាក់ក្នុងមួយខែចំនួន ៣០០USD នោះទេ ។ ដូច្នេះ សុំឱ្យតុលាការពិនិត្យពិចារណាលើការបង់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព ។ ម្យ៉ាងវិញទៀត ដើមចោទឈ្មោះ[redacted] វូចស៊ាង បានយកតូបលេខ៣៥៦ ទៅជួលឱ្យអ្នកដទៃដោយបានកម្រៃក្នុងមួយខែចំនួន ៥០០USD ។

សំណូមពរ: សុំឱ្យតុលាការសម្រេចតាមការប្តឹងសុំរបស់កូនក្តីខ្លួនឈ្មោះ[redacted] សុភាណា ។

៣-តំណាងអយ្យការលោក[redacted] បានបញ្ចេញយោបល់ថា: រឿងក្តីនេះមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងផលប្រយោជន៍សាធារណៈនោះទេ ។ ម្យ៉ាងវិញទៀត គូភាគីបានឯកភាពគ្នាក្នុងការប្រគល់សិទ្ធិគ្រប់គ្រងកូនដែលជាអនីតិជន គ្រាន់តែគូភាគីមិនឯកភាពគ្នាក្នុងការបង់អាហារកិច្ចចិញ្ចឹមកូន និងការបែងចែកទ្រព្យរួមប៉ុណ្ណោះ ។ ដូច្នេះសុំឱ្យតុលាការសម្រេចតាមច្បាប់ ។

## **<u>ការសំអាងហេតុ</u>**

១-ដើមចោទឈ្មោះ[redacted] វូចស៊ាង និងចុងចម្លើយឈ្មោះ[redacted] សុភាណា ជាប្តីប្រពន្ធដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវស្របតាមបញ្ញត្តិច្បាប់មាត្រា១៤ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៨៩ ។ ប៉ុន្តែ គូភាគីបានរស់នៅជាមួយគ្នាជាប្តីប្រពន្ធយូរណាស់មកហើយ ។ ដូច្នេះ ការប្តឹងសុំឈប់រស់នៅជាអនីតិសង្វាសពីប្តីឈ្មោះ[redacted] សុភាណា របស់ដើមចោទឈ្មោះ[redacted] វូចស៊ាង គប្បី តុលាការពិចារណា ។

២-គូភាគីបានថ្លែងការណ៍ថា: ការរស់នៅជាប្តីប្រពន្ធមានកូនបីនាក់គឺ ក-ឈ្មោះ[redacted] សុគារ៉ា ភេទប្រុស ទី០២.០១.១៩៩២ ខ-ឈ្មោះ[redacted] សោរ៉ីមករា ភេទប្រុស កើតនៅថ្ងៃទី២៧.០១.១៩៩៦ និងគ-ឈ្មោះ[redacted] ភេទស្រី កើតនៅថ្ងៃទី២១.០៩.២០០៦។ ចំពោះកូនឈ្មោះ[redacted] សោរ៉ីមករា និងឈ្មោះ[redacted] គឹមលាង គឺចុងចម្លើយឈ្មោះ[redacted] សុគារណា បានឯកភាពក្នុងការប្រគល់សិទ្ធិគ្រប់គ្រងកូនឱ្យទៅដើមចោទឈ្មោះ[redacted] ទូចស៊ាង តាមការប្តឹងសុំ ដោយចុងចម្លើយឈ្មោះ[redacted] សុគារណា ប្តឹងសុំបង់អាហារកិច្ចចិញ្ចឹមកូនទាំងពីរនាក់តាមលទ្ធភាព។ ផ្ទុយទៅវិញ ដើមចោទឈ្មោះ[redacted] ទូចស៊ាង ប្តឹងសុំទាមទារអាហារកិច្ចចិញ្ចឹមកូនទាំងពីរនាក់ក្នុងមួយខែចំនួន ៣០០USD។ រីឯ កូនប្រុសឈ្មោះ[redacted] សុគារ៉ា គឺជានីតិជន។ គប្បីតុលាការសម្រេចប្រគល់សិទ្ធិគ្រប់គ្រងកូនជាអនីតិជនតាមការព្រមព្រៀង និងពិចារណាលើអាហារ-កិច្ចចិញ្ចឹមកូន។

៣-គូភាគីបានថ្លែងការណ៍ថា: ចំពោះទ្រព្យដោយឡែក គឺគ្មានទេ។ ចំណែកឯ ទ្រព្យរួម មាន:

ក-ផ្ទះលេខ៥៤AE$_0$E$_1$ ផ្លូវលេខ២០៤ ក្រុមទី១៥ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ១៣៨៨/០៧ ចុះថ្ងៃទី០១.០៨.២០០៧ របស់អភិបាលខណ្ឌទួលគោក។

ខ-ដីទំហំ ២៩៥០ម៉ែត្រការេ មានទីតាំងស្ថិតនៅភូមិបង្គោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ៤៤៩/០៨ ឃអព ចុះថ្ងៃទី២១.០៨.២០០៨ របស់មេឃុំអំពិល។

គ-សិទ្ធិជួលតូបលេខ៣៥៦ និងលេខ៣៦៦ អាគារ C$_0$ ក្នុងមជ្ឈមណ្ឌលពាណិជ្ជកម្មអូឡាំពិច។

ចំពោះការថ្លែងការណ៍របស់គូភាគីលើទ្រព្យរួមខាងលើ គឺគូភាគីបានប្តឹងសុំក្នុងការបែងចែកទ្រព្យរួម។ លើកលែងតែសិទ្ធិជួលតូបលេខ៣៥៦ និងលេខ៣៦៦ អាគារ C$_0$ ក្នុងមជ្ឈមណ្ឌលពាណិជ្ជកម្មអូឡាំពិច ដែលដើមចោទឈ្មោះ[redacted] ទូចស៊ាង ប្តឹងសុំសិទ្ធិគ្រប់គ្រងតែម្នាក់ឯង ដោយសំអាងថា: ខ្លួនមានអាជីពក្នុងការប្រកបរបររកស៊ីលើតូបនេះក្នុងការផ្គត់ផ្គង់ជីវភាពកូនៗដែលនៅក្នុងបន្ទុក។ ដូច្នេះ គប្បី តុលាការពិចារណាក្នុងការបែងចែកទ្រព្យរួម និងពិចារណាលើការប្តឹងសុំគ្រប់គ្រងសិទ្ធិជួលតូបទាំងពីររបស់ដើមចោទដោយពិចារណាលើផលប្រយោជន៍ក្នុងការចិញ្ចឹមកូន និងអាជីពជាប្រចាំរបស់ដើមចោទឈ្មោះ[redacted] ទូចស៊ាង។

៤-ដើមចោទឈ្មោះ[redacted] ទូចស៊ាង បានថ្លែងការណ៍ថា: បំណុលរួមមានប្រាក់ចំនួន ១០៨,៨៨៤USD។ ប៉ុន្តែ ចុងចម្លើយឈ្មោះ[redacted] សុគារណា មិនទទួលស្គាល់លើបំណុលរួមនេះឡើយ។ម្យ៉ាងទៀត ភស្តុតាងដែលដើមចោទបានដាក់ជូនឱ្យតុលាការពិនិត្យនោះ គឺត្រូវបានធ្វើឡើងដោយមិនត្រឹមត្រូវស្របតាមមាត្រា៣៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ និងមាត្រា១៥៥ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។ គប្បី តុលាការមិនពិចារណាលើបំណុលនេះឡើយ។

៥-ចំពោះប្រាក់ប្រដាប់ក្តី គឺដើមចោទឈ្មោះ[redacted] ទូចស៊ាង សុខចិត្តទទួលបន្ទុក។

## សេចក្តីសម្រេចបញ្ចប់

១-ទទួលស្គាល់ការឈប់រស់នៅជាអនីតិសង្វាសរវាងឈ្មោះ[redacted] សុគារណា និងនាងឈ្មោះ[redacted] ទូចស៊ាង (តាមការ-ព្រមព្រៀង)។



Scanned with CamScanner

២.ក.ប្រគល់កូន:

ក.១.ឈ្មោះ [redacted] សៅរីមករា ភេទប្រុស កើតនៅថ្ងៃទី២៧.០១.១៩៩៦។

ក.២.ឈ្មោះ [redacted] គីមឈាង ភេទស្រី កើតនៅថ្ងៃទី២១.០៩.២០០៦។

ឱ្យនៅជាមួយដើមចោទឈ្មោះ [redacted] ទូចស៊ាង (តាមការព្រមព្រៀង) ចាប់ពីថ្ងៃប្រកាសសាលក្រម។

ខ.បង្គាប់ឱ្យឈ្មោះ [redacted] សុភាណា បង់រាប់ការកិច្ចចិញ្ចឹមកូនទាំងពីរនាក់ ក្នុងមួយខែចំនួន ១០០០.០០០រៀល (មួយលានរៀល) ឱ្យទៅឈ្មោះ [redacted] ទូចស៊ាង រហូតដល់កូនបាននីតិភាព។

ដោយដើមចោទមានកាតព្វកិច្ចបីបាច់រក្សាកូន។ ចុងចម្លើយឈ្មោះ [redacted] សុភាណា ដែលមិនបានរក្សាកូនមានសិទ្ធិទៅសួរសុខទុក្ខកូនដោយដើមចោទឈ្មោះ [redacted] ទូចស៊ាង ត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាង។

តាមមាត្រា៧២.៧៣.៧៤ និង៧៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៨៩។

៣.ប្រគល់ទ្រព្យរួម ជូន:

ក.ផ្ទះលេខ៥៤AE,E1 ផ្លូវលេខ២០៤ ក្រុមទី១៥ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ១៣៨៨/០៧ ចុះថ្ងៃទី០១.០៨.២០០៧ របស់អភិបាលខណ្ឌទួលគោក។

ខ.ដីទំហំ ២៥៥០ម៉ែត្រការេ មានទីតាំងស្ថិតនៅភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ៤៤៩/០៨ ឃអព ចុះថ្ងៃទី២១.០៨.២០០៨ របស់មេឃុំអំពិល។

ឱ្យនៅដើមចោទឈ្មោះ [redacted] ទូចស៊ាង និងចុងចម្លើយឈ្មោះ [redacted] សុភាណា ជាពីរចំណែកស្មើៗគ្នាតាមតម្លៃ-ជាក់ស្តែង ចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ។

គ.សិទ្ធិជួលតូបលេខ៣៥៦ និងលេខ៣៦៦ អាគារ $C_0$ ក្នុងមជ្ឈមណ្ឌលពាណិជ្ជកម្មអូឡាំពិច ឱ្យទៅដើមចោទឈ្មោះ [redacted] ទូចស៊ាង ចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ។

តាមមាត្រា៧០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៨៩។

៤.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទតាមការព្រមព្រៀង ដែលប្រាក់នេះត្រូវបានបង់រួចហើយ។

ចៅក្រម

ហត្ថលេខា និងត្រា : [redacted]

---

បានឃើញ

ចៅក្រម

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែសីហា ឆ្នាំ២០១១

ក្រឡាបញ្ជី

[redacted]

៥៣៦៤